# របាយការណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិក
# របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០១១
# ប្រទេសកម្ពុជា - (លំដាប់ថ្នាក់ទី ២)

កម្ពុជាគឺជាប្រទេសប្រភព និងជាប្រទេសឆ្លងកាត់ និងជាប្រទេសគោលដៅសំរាប់បុរស ស្ត្រី និង កុមារ ដែលរងគ្រោះដោយការចាប់បង្ខំអោយធ្វើពលកម្ម និងការជួញដូរផ្លូវភេទ ។ បុរស ស្ត្រីនិង កុមារកម្ពុជាធ្វើចំណាកស្រុកទៅប្រទេសថៃ ប្រទេសម៉ាឡេស៊ី និងប្រទេសដទៃទៀ ដើម្បីរកការងារធ្វើ ហើយនៅពេលបន្ទាប់មក ពួកគេជាច្រើនអ្នកបានធ្លាក់ទៅក្នុងការជួញដូរផ្លូវភេទ ឬត្រូវបានគេបង្ខំអោយធ្វើពលកម្មធ្ងន់ធ្ងក្នុងឧស្សាហកម្មកែច្នៃអាហារសមុទ្រ និងការនេសាទរបស់ថៃ តាមចំការកសិកម្មធំៗ តាមរោងចក្រ ការងារបំរើតាមផ្ទះ សុំទានគេ និងការលក់ដូរតាមផ្លូវ។ ចំនួនពលករដែលធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី ដើម្បីរកការងារធ្វើតាមរយៈក្រុមហ៊ុនជ្រើសរើស មានកំណើនយ៉ាងច្រើនគួរអោយកត់សំគាល់ចាប់តាំង ពីឆ្នាំ២០០៨ មក។ នៅឆ្នាំ២០១០ ក្រុមហ៊ុនជ្រើសរើសពលករកម្ពុជាមានការអនុញ្ញាត ដែលជាសមាជិកនៃ សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា បានបង្រៀន និងបញ្ជូនពលករចំនួន ១៦ ៣៩៥ ទៅប្រទេសម៉ាឡេស៊ី ដែលក្នុងចំណោមនេះ មាន ១១ ៩១៨ គឺជាស្ត្រីបំរើតាមផ្ទះ។ ចំនួននេះកើនពីចំនួន ៩ ៩៨២ ដែលបានធ្វើចំណាកស្រុកទៅកាន់ប្រទេសម៉ាឡេស៊ី នៅឆ្នាំ ២០០៩ និងចំនួន ២ ៦៥៤ នៅឆ្នាំ ២០០៨។ អ្នកធ្វើចំណាកស្រុកខ្មែរខ្លះបានក្លាយជាជនរងគ្រោះដោយការជួញដូរពលកម្ម ក្នុងការដែលគេស្វែងរកការងារនៅបរទេស ដែលគេគិតថាជាការងារត្រឹមត្រូវស្របច្បាប់ តែត្រូវបានបង្ខំអោយធ្លាក់ទៅក្នុងទាសភាពបំណុល។

ថ្វីត្បិតថៃការធ្វើបែបនេះត្រូវបានហាមប្រាមនៅចុងឆ្នាំ ២០១០ ក្តី ក៏ជាធម្មតា ទីភ្នាក់ងារធ្វើការជ្រើសរើសតំរូវអោយគ្រួសារនៃជនជាតិខ្មែរដែលធ្វើដំណើរទៅរកការងារធ្វើនៅប្រទេសម៉ាឡេស៊ី ព្រមសងលុយកម្ចីនៅមុនពេលចេញដំណើរ ដែលនេះគឺជាមធ្យោបាយចាប់អោយពលករដែលចេញដំណើរទៅនោះបំពេញកុងត្រាការងារ នៅប្រទេសម៉ាឡេស៊ី។ ពលករខ្លះមិនយល់ពីអ្វីដែលគេត្រូវបំពេញ ឬមិនចេះអានកុងត្រា ដែលនិយាយពីការដកប្រាក់ចំនួនពី ៨០០ ទៅ ១២០០ ដុល្លា សំរាប់ថ្លៃរកកន្លែងការងារអោយធ្វើ និង ថ្លៃ ក្រដាសស្នាមផ្សេងៗ ពីអនាគតប្រាក់ខែរបស់ពលករនៅក្នុងប្រទេសគោលដៅ ។ ប្រាក់កាត់ទាំងនេះស្មើនឹងប្រាក់ខែរបស់គេពី ៤ ខែទៅ ១ ឆ្នាំ។ អ្នកធ្វើការដទៃទៀតយល់ព្រមជាមួយលក្ខខ័ណ្ឌ ពីព្រោះថា គេគ្មានឱកាសណាផ្សេងទៀតដើម្បីទាញខ្លួនអោយចេញផុតពីភាពក្រីក្រទេ ថ្វីត្បិតតែត្រូវប្រឈមនឹងការប្រថុយ ហើយនិងការកាត់ប្រាក់ខែក្តី។ ពេលខ្លះ ពលករមិនត្រូវបានគេផ្តល់សំណៅនៃកុងត្រាការងាររបស់គេអោយទេ ហើយជាធម្មតា ត្រូវបានគេដកហូតលិខិតឆ្លងដែនទុក។ ទីភ្នាក់ងារជ្រើសរើសថែមទាំងត្រូវបាន

រាយការណ៍មកថា បានកែបន្លំឯកសារអត្តសញ្ញាណនិងឯកសារអាយុត្រឹមត្រូវ ដើម្បីអាចធ្វើការជ្រើសរើសកុមារដោយមិនស្របច្បាប់។ ក្នុងរយៈពេលនៃការរៀនសូត្រពី ៣ ខែទៅ ៦ ខែ ទីភ្នាក់ងារជ្រើសរើសពលករច្រើនតែដាក់កំហិតមិនអោយស្ត្រី និងកុមារចាកចេញពីមជ្ឈមណ្ឌលរៀនសូត្រ ដោយពេលខ្លះតំរូវអោយបង់លុយយ៉ាងច្រើន បើសិនជាគេចាកចេញដោយរំលោភលើកុងត្រារបស់គេ។ នៅពេលទៅដល់ប្រទេសម៉ាឡេស៊ីពលករបំរើតាមផ្ទះខ្លះបានរាយការណ៍ពីលក្ខណៈបែបជួញដូរ ដូចជាការធ្វើការច្រើនម៉ោង គ្មានថ្ងៃឈប់សំរាកគ្មានលទ្ធភាពចាកចេញពីកន្លែងការងារ ការមិនបង់ប្រាក់ខែអោយ ការបង់ប្រាក់ឈ្នួលយឺត និងការកាត់ប្រាក់ឈ្នួល។ ការទារថ្លៃខ្ពស់ និងការរំលោភបំពានទាំងនេះត្រូវបានប្រើជាការបង្ករលក្ខណៈសំរាប់ពលកម្មដោយការបង្ខំ និងទាសភាពបំណុលទៅលើពលករចំណាកស្រុកនៅប្រទេសម៉ាឡេស៊ី។

ក្នុងឆ្នាំរបាយការណ៍នេះ បុរសខ្មែរដែលជាជនរងគ្រោះដោយការបង្ខំអោយធ្វើពលកម្មនៅលើទូកនេសាទ ត្រូវបានគេបញ្ជូនមកពីប្រទេសឥណ្ឌា ថៃ និងប្រទេសម៉ាឡេស៊ីវិញ។ ការសិក្សាមួយរបស់អង្គការសហប្រជាជាតិបានធ្វើការប៉ាន់ប្រមាណថា ក្នុងចំណោមជនជាតិខ្មែរចំនួន ៨៩ ០០០ នាក់ដែលត្រូវបានចាប់បញ្ជូនត្រឡប់មកពីប្រទេសថៃវិញ តាមច្រកប៉ោយប៉ែតតែមួយ មាន ២០ ០០០ គឺជាជនរងគ្រោះដោយការជួញដូរ ដោយមិនត្រូវបានដឹងដោយអាជ្ញាធរថៃ។ បុរសខ្មែរខ្លះបាននិយាយថា ខ្លួនត្រូវបានបោកប្រាសដោយម្ចាស់ទូកនេសាទថៃពីរយៈពេលធ្វើការ ចំនួន និងវិធីនៃការបង់ប្រាក់ឈ្នួល។ ដោយនៅលើទូកអស់រយៈពេលរាប់ឆ្នាំ មានខ្លះបានឃើញការធ្វើបាបដោយម្ចាស់ទូកថៃ រួមទាំងអំពើហឹង្សា និងការសំលាប់អ្នកនេសាទដូចគ្នា។ កុមារខ្មែរក៏ត្រូវបាននាំឆ្លងដែនចូលប្រទេសថៃ និងវៀតណាមផងដែរ ដោយអ្នកប្រព្រឹត្តការជួញដូរជាជនជាតិខ្មែរ ហើយត្រូវបានបង្ខំអោយដើរសុំទាន លក់ស្ករគ្រាប់ និងផ្កា ហើយនិងខាត់ស្បែកជើង។ ពេលខ្លះឪពុកម្តាយលក់កូនអោយគេបង្ខំប្រើ រួមទាំងការធ្វើជាអ្នកបំរើក្នុងផ្ទះ។ ក្រុមឧក្រិដ្ឋជនវៀតណាមដែលមានការចាត់តាំងបាននាំស្ត្រី និងកុមារវៀតណាមឆ្លងកាត់ប្រទេសប្រទេសកម្ពុជាទៅប្រទេសថៃ និងម៉ាឡេស៊ីដើម្បីអោយបំរើពេស្យាចារដោយបង្ខំ និងពេស្យាចារ្យកុមារ។

នៅប្រទេសកម្ពុជា ស្ត្រីនិងកុមារវៀតណាម និងកម្ពុជាត្រូវបានគេជួញដូរពីតំបន់ជនបទមកក្រុងភ្នំពេញ សៀមរាប ប៉ោយប៉ែត កោះកុង ទីក្រុងព្រះសីហនុ និងស្វាយប៉ាក ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ។ កន្លែងកំសាន្តធំៗខ្លះអាចមានស្ត្រីនិងកុមារពី ១០០ ទៅ ២០០ នាក់នៅកន្លែងនោះក្នុងមួយយប់។ ដើម្បីជៀសវាងការចាប់យកទៅកាត់ទោស កន្លែងទាំងនេះជាច្រើនបានឈប់ផ្តល់សេវាផ្លូវភេទនៅនឹងកន្លែង ដោយអោយអតិថិជនយកស្ត្រី និងកុមារីទៅក្រៅជំនួសវិញ។ ក្នុងលក្ខណៈដូចគ្នានេះដែរ កុមារមិនទាន់គ្រប់អាយុ ដែលភាគច្រើនត្រូវបាននាំយកមកពីប្រទេសវៀតណាម មានផ្តល់តាមការចង់បាននៅតាមផ្ទះបន និងផ្ទះសំណាក់នៅតំបន់ស្វាយប៉ាក តែគេមិនទុកនៅនឹងកន្លែងទេ។ កុមារក៏ត្រូវបានគេបង្ខំអោយធ្វើពលកម្មដែរ ដោយរួមទាំងត្រូវបានបង្ខំអោយដើរសុំទាន រើសសំរាម ធ្វើការតាមកន្លែងយកថ្ម ជាអ្នកបំរើតាមផ្ទះ ឬក្នុងការធ្វើនិងកែ

ថ្នៃអិដ្ឋ កៅស៊ូ អំបិល និងបង្គារ។ បើយោងតាមអង្គការពលកម្មអន្តរជាតិ គ្រាន់តែនៅក្រុងភ្នំពេញមួយ មានកុមារបំរើតាមផ្ទះចំនួនប្រមាណ ២៨ ០០០ នាក់។ ប្រទេសកម្ពុជាគឺជាគោលដៅដែលគេនាំស្ត្រីនិងកុមារវៀតណាមមកអោយបំរើពេស្យាចារ ដែលភាគច្រើននៃពួកគេត្រូវជាប់ទាសភាពបំណុល។ ការលក់កុមារព្រហ្មចារីនៅតែជាបញ្ហាធ្ងន់ធ្ងរមួយនៅប្រទេសកម្ពុជា ដោយបុរសខ្មែរនិងបរទេស (ដែលភាគច្រើនមកពីតំបន់អាស៊ី) រាប់សែនដុល្លាដើម្បីបានរួមភេទជាមួយអ្នកនៅមានព្រហ្មចារី។ បុរសអាស៊ី និងបុរសបរទេសដទៃទៀតជាច្រើនបានធ្វើដំណើរមកប្រទេសកម្ពុជា ជាទេសចរផ្លូវភេទលើកុមារ។ ជនជាតិខ្មែរខ្លះដែលធ្វើចំណាកស្រុកទៅកាន់កោះតៃវ៉ាន់ និងសាធារណរដ្ឋកូរេតាមរយៈក្រុមហ៊ុនរៀបចំអាពាហ៍ពិពាហ៍អន្តរជាតិនៅទីបំផុតត្រូវបានបង្ខំអោយបំរើពេស្យាចារ ឬបង្ខំអោយធ្វើពលកម្ម។ ការបង្ខំអោយធ្វើពលកម្មនៅតាមមជ្ឈមណ្ឌលបន្សាបគ្រឿងញៀន ដែលក្នុងនោះអ្នកញៀនគ្រឿងញៀនដែលជាប់ទោសរដ្ឋបាល ត្រូវបានគេបង្ខំអោយធ្វីការងារកម្មករក៏ជាកង្វល់មួយដែរ។

រដ្ឋាភិបាលកម្ពុជាមិនបានគោរពបានពេញលេញលើបទដ្ឋានអប្បរិមាសំរាប់ការបំបាត់ការជួញដូរទេ។ ប៉ុន្តែកំពុងតែខិតខំច្រើនគួរសមក្នុងការងារនេះ។ រដ្ឋាភិបាលបានបន្តកាត់ទោសករណីជួញដូរផ្លូវភេទដោយបានដាក់ទោសដល់ជនប្រព្រឹត្តការជួញដូរចំនួន ២០ នាក់ក្នុងឆ្នាំនៃរបាយការណ៍ ដែលជាចំនួនថយពី ៣៦ នៃឆ្នាំរបាយការណ៍មុន។ អំពើពុករលួយនៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៅតែជាឧបសគ្គដល់ភាពជឿនលឿនក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ហើយបានធ្វើអោយមានបរិយាកាសអនុគ្រោះសំរាប់ការជួញដូរ។ ការជួញដូរពលកម្មលើជនជាតិខ្មែរដែលធ្វើចំណាកស្រុកទៅបរទេសដើម្បីស្វែងរកការងារធ្វើនៅតែជាកង្វល់ដ៏ធ្ងន់ធ្ងរនៅឡើយ។ រដ្ឋាភិបាលមិនដែលកាត់ទោសអ្នកជ្រើសរើសមនុស្សអោយទៅធ្វើការទេ ដែលក្រុមហ៊ុនរបស់គេមានការពាក់ព័ន្ធនឹងការជួញដូរពលករ ឬការជ្រើសរើសពលករដោយការបន្លំ។

## អនុសាសន៍សំរាប់ប្រទេសកម្ពុជា

បង្កើនកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេត និងនាំមកកាត់ទោសអោយខ្លាំងនូវជនល្មើសជួញដូរពលកម្ម និងផ្លូវភេទ ធ្វើការស៊ើបអង្កេត និងនាំមកកាត់ទោសអោយបានហ្មត់ចត់នូវមន្ត្រីរដ្ឋាភិបាលដែលមានការពាក់ព័ន្ធក្នុងសកម្មភាពជួញដូរ ដាក់ចេញ និងអនុវត្តច្បាប់ដើម្បីធ្វើអោយប្រសើរឡើងក្នុងការគ្រប់គ្រងការជ្រើសរើសមនុស្ស ការរកកន្លែងការងារអោយ និងការការពារពលករចំណាកស្រុកនៅបរទេស ដាក់អោយក្រុមហ៊ុនជ្រើសរើសពលករទទួលខុសត្រូវលើអំពើឧក្រិដ្ឋ ខុសច្បាប់ ដែលប្រព្រឹត្តឡើងក្នុង ដំណើរការជ្រើសរើស ដូចជាទាសភាពបំណុលតាមរយៈតំលៃសេវាដ៏លើសលុប ការឃុំឃាំងពលករក្នុងកំឡុងពេលបណ្តុះបណ្តាលមុនចេញដំណើរ និងការជ្រើសរើសពលករក្រោមអាយុ ១៨ ឆ្នាំ បង្កើនកិច្ចខិតខំប្រឹងប្រែង

ដើម្បីអោយដំណើរការរបស់តុលាការឆ្លើយតបទៅនិងសេចក្តីត្រូវការ និងផលប្រយោជន៍របស់ជនរងគ្រោះដោយការជួញដូរ ទាំងកុមារ និងមនុស្សពេញវ័យ ពង្រីកកិច្ចខិតខំប្រឹងប្រែងអោយសកម្មដើម្បីកំនត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរ ក្នុងចំណោមក្រុមងាយរងគ្រោះ ដោយរាប់បញ្ចូលការបង្កើតនិតិវិធីកំណត់អត្តសញ្ញាណជនរងគ្រោះថ្នាក់ជាតិ និង ការបញ្ជូនជនរងគ្រោះបន្ត ទៅសេវាជនរងគ្រោះគ្រប់គ្រាន់ បង្កើនទំនាក់ទំនងជាមួយរដ្ឋាភិបាលនៃប្រទេសគោលដៅ ក្នុងការការពារពលករចំណាកស្រុក ក៏ដូចជាការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាពនៃជនរងគ្រោះកម្ពុជាដោយការជួញដូរ និងនាំមកកាត់ទោសនូវអ្នកប្រព្រឹត្តការជួញដូរពួកគេ បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការបណ្តុះបណ្តាល និងធ្វើអោយយល់ដឹងដល់មន្ត្រីអនុវត្តច្បាប់ ព្រះរាជអជ្ញា និងមន្ត្រីតុលាការលើការជួញដូរ កំណត់យ៉ាងសកម្មនូវអត្តសញ្ញាណជនរងគ្រោះ និតិវិធីនៃការបញ្ជូនជនរងគ្រោះបន្ត និង ដោះស្រាយករណីដោយយកចិត្តទុកដាក់លើការប៉ះពាល់ដល់ជនរងគ្រោះ  បង្កើនការសហការនិងសំរបសំរួលជាអន្តរទីភ្នាក់ងារ រវាងមន្ត្រីប៉ូលីស និងមន្ត្រីតុលាការលើករណីជួញដូរ ដឹកនាំយុទ្ធនាការយល់ដឹងជាសាធារណៈ សំដៅកាត់បន្ថយតម្រូវការរបស់មនុស្សក្នុងស្រុក និងទេសចរអាស៊ីលើសកម្មភាពផ្លូវភេទដែលមានលក្ខណៈជួញដូរ។

## ការនាំខ្លួនយកមកកាត់ទោស

រដ្ឋាភិបាលកម្ពុជាមិនបានបង្ហាញអោយឃើញនូវភាពជឿនលឿនក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ខ្លួនទេ នៅក្នុងឆ្នាំនៃរបាយការណ៍នេះ ។ ច្បាប់ចេញនៅខែកុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ មាននិយាយពីទោសផ្សេងៗ ដោយមានមាត្រាចំនួន ១២ ក្នុងចំណោមមាត្រាចំនួន ៣០ និយាយច្បាស់ពីទោសក្នុងការជួញដូរ ។ ច្បាប់នេះហាមប្រាមគ្រប់ទំរង់ទាំងអស់នៃការជួញដូរមនុស្ស ហើយចែងពីការដាក់ទោសដែលមានភាពម៉ឺងម៉ាត់គ្រប់គ្រាន់ និងស្របតាមទោសសំរាប់បទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ដូចជាការរំលោភសេពសន្ថវៈ ។  មន្ត្រីរដ្ឋាភិបាលបានរាយការណ៍ពីការបានកាត់ទោសករណីជួញដូរចំនួន ៧២ ករណី និងបានដាក់ទោសលើជនល្មើសចំនួន ២០ នាក់ ចំណែកនៅឆ្នាំ ២០០៩ មានការដាក់ទោសលើជនល្មើសចំនួន ៣៦ នាក់។ ថ្វីបើការជួញដូរពលករនៅតែជាកង្វល់ធំមួយនៅឡើយក្តី តែក្នុងឆ្នាំនៃរបាយការណ៍នេះ គ្មានការកាត់និងដាក់ទោសលើជនល្មើសជួញដូរពលករទេ ហើយរដ្ឋាភិបាលមិនទាន់ដាក់ទោសលើអ្នកជ្រើសរើសពលករ ដែលក្រុមហ៊ុនរបស់គេមានការពាក់ព័ន្ធក្នុងការជួញដូរ ឬជ្រើសរើសពលករដោយការបន្លំទេ។ ពេលខ្លះព្រះរាជអាជ្ញាមិនបានធ្វើការចោទប្រកាន់ជនល្មើសដោយការជួញដូរ ដោយប្រើមាត្រាដ៏សមស្របបំផុតនៃច្បាប់ឆ្នាំ ២០០៨ ទេ។ ក្នុងករណីខ្លះនគរបាលកម្ពុជាមិនចង់បន្តការស៊ើបអង្កេតលើកន្លែងជួញដូរមួយចំនួនដែលត្រូវបានសង្ស័យទៅលើ ក្នុងឆ្នាំ

នៃរបាយការណ៍នេះ ដោយសារកន្លែងនោះជារបស់មន្ត្រីជាន់ខ្ពស់ ឬមានខ្សែជាមួយមន្ត្រីជាន់ខ្ពស់។ ការផ្លាយចេញព័ត៌មានដោយសមត្ថកិច្ចដល់ជនប្រព្រឹត្តការជួញដូរត្រូវបានរាយការណ៍មកថា បានធ្វើអោយខូចយ៉ាងខ្លាំងដល់ការខិតខំអនុវត្តច្បាប់ប្រឆាំងការជួញដូរ។ ទោះបីជាក្រសួងការងារបានដឹងពីការរំលោភបំពានដល់កម្មករចំណាកស្រុកវ័យជំទង់និងកុមារ ដោយក្រុមហ៊ុនជ្រើសរើសកម្មករដែលមានអាជ្ញាបណ្ណក្នុងស្រុកនិងក្រៅស្រុកក្តី ក្រសួងមិនបានដោះស្រាយបញ្ហានេះអោយបានគ្រប់គ្រាន់ទេ។

ប្រភពមួយចំនួនបាននិយាយថា ទីភ្នាក់ងារជ្រើសរើសពលករមួយចំនួន ដែលរងការចោទប្រកាន់ថាមានការពាក់ព័ន្ធនឹងការជួញដូរពលករ មានខ្សែរយៈជាមួយមន្ត្រីជាន់ខ្ពស់កម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា បានឃើញការជ្រើសរើស ការឃុំខ្លួនមិនអោយដើរទៅណា និងការដាក់អោយកុមារធ្វើការដោយទីភ្នាក់ងារជ្រើសរើសពលករ នៅបរទេស ហើយបានផ្ញើព័ត៌មានស្តីពីករណីនេះទៅអាជ្ញាធរ តែបានសំដែងកង្វល់ថា អាជ្ញាធរមិនមានការឆ្លើយតប ឬចាត់ការលើរបាយការណ៍ទាំងនេះទេ។ ដូចត្រូវបាននិយាយក្នុងរបាយការណ៍មុន អ្នកជ្រើសរើសពលករម្នាក់ត្រូវបានចាប់ខ្លួន នៅខែធ្នូ ឆ្នាំ ២០០៩ ចំពោះការនាំក្មេងចំនួន ៩ នាក់ដោយខុសច្បាប់ ក្នុងបំណងលក់ពួកគេអោយធ្វើការជាអ្នកបំរើ នៅប្រទេសម៉ាឡេស៊ី ។ អ្នកជ្រើសរើសមនុស្សនោះត្រូវបានដោះលែងវិញដោយមានការបង់ប្រាក់អោយនៅក្រៅឃុំ នៅខែមេសា ឆ្នាំ ២០១០។ អាជ្ញាធរបានរាយការណ៍ពីការផ្តើមការកាត់ទោសនិងដាក់ទោសលើក្រុមហ៊ុនជ្រើសរើសពលករកម្ពុជា ពីបទពង្រាត់ ឃុំខ្លួននៅមួយកន្លែងលើនារី និងកុមារ ដែលត្រូវបានជ្រើសរើសអោយទៅធ្វើការនៅបរទេស។ ជនសង្ស័យនៅកំពុងជាប់ឃុំឃាំងនៅឡើយ តែគេមិនទាន់កំណត់ថ្ងៃខែសវនាការនៅឡើយទេក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ រដ្ឋាភិបាលបានបន្តធ្វើសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអប់រំមន្ត្រីនគរបាល និងមន្ត្រីរដ្ឋាភិបាលដទៃទៀត ស្តីពីច្បាប់ឆ្នាំ ២០០៨ និងការអនុវត្តច្បាប់នេះ។ យ៉ាងណាក្តី ការច្រឡំដែលនៅតែមានរបស់នគរបាល និងតុលាការទាក់ទងនឹងការជួញដូរមនុស្ស និងច្បាប់ឆ្នាំ ២០០៨ មានការប៉ះពាល់ដល់ការខិតខំក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរ និងការខិតខំការពារជនរងគ្រោះ។ ចៅក្រម និងព្រះរាជអាជ្ញានៅតែបន្តការចោទប្រកាន់មិនចំចំពោះជនល្មើសក្នុងការជួញដូរ ក្រោមមាត្រានិងច្បាប់ស្តីពីការមិនជួញដូរ  ឬកាត់ទោសករណីមិនជួញដូរ ដោយប្រើលក្ខខ័ន្តិកៈស្តីពីការជួញដូរ ដែលនាំអោយមានការពិបាកក្នុងការញែកពីគ្នានូវករណីជួញដូរ និងមិនជួញដូរ។ ការខ្វះការសំរបសំរួលគ្នារវាងនគរបាលស៊ើបអង្កេត និងនិងព្រះរាជអាជ្ញានៅតែធ្វើអោយរាំងស្ទះដល់ការនាំយកមកកាត់ទោសពិតប្រាកដនូវជនល្មើសដោយការជួញដូរ ចំណែកឯការពន្យាពេលសវនាការដោយសារមេធាវីចុងចោទ និងចៅក្រមគ្មានវត្តមានក៏បណ្តាលអោយមានបញ្ហាដូចគ្នានេះដែរ។ ក្នុងករណីខ្លះ មន្ត្រីតុលាការថែមទាំងខកខានមិនបានជំរាបភាគីពីពេលវេលានៃការបន្តសវនាការបែបនេះទេ។ ការពន្យាពេលបែបនេះបណ្តាលអោយមានការបារម្ភសំរាប់ជនរងគ្រោះ ដែល

មួយចំនួនធំគឺជាកុមារ ហើយត្រូវការការរៀបចំបន្ថែម និងការធ្វើដំណើរសំរាប់សវនាការ។ ក្នុងឆ្នាំនៃរបាយការណ៍នេះ មានការថយចុះក្នុងចំនួននៃការសង្គ្រោះជនរងគ្រោះ និងការចាប់ខ្លួនជនល្មើស។

ក្នុងឆ្នាំដដែលនេះ រដ្ឋាភិបាលបានអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ នៅខែមេសា ឆ្នាំ ២០១០ ហើយបានប្រកាសនយោបាយ “កំរិតសូន្យនៃការអត់ឱន” ចំពោះមន្ត្រីពុករលួយ។ យ៉ាងណាក្តី អំពើពុករលួយដែលមាននៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៅតែបង្កើតអោយមានបរិយាកាសអនុគ្រោះសំរាប់ការជួញដូរ ហើយក្នុងករណីខ្លះ ជួយសំរួលយ៉ាងសកម្មដល់ការជួញដូរ។ មន្ត្រីនគរបាល និងមន្ត្រីតុលាការបន្តមានការពាក់ព័ន្ធដោយផ្ទាល់ និងដោយមិនផ្ទាល់ក្នុងការជួញដូរ។ ប្រភពមួយបាននិយាយថា កន្លែងកំសាន្តខ្លះដែលមានការពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ មានខ្សែជាមួយមន្ត្រី។ នគរបាលមូលដ្ឋាន និងមន្ត្រីរដ្ឋាភិបាលខ្លះបានជំរិតទារប្រាក់ ឬទទួលសំណូកពីម្ចាស់ផ្ទះបន ដែលក្នុងករណីខ្លះទាររាល់ថ្ងៃជាថ្នូរនឹងការ អនុញ្ញាតអោយផ្ទះបនទាំងនោះបន្តបើកតទៅទៀតបាន។ ការប្រាប់របស់នគរបាលពីការឆ្មក់ទៅលើផ្ទះបនជាការប្រឆាំងការជួញដូរមនុស្ស នៅតែបន្តធ្វើអោយមានការជ្រៀតជ្រែកទៅលើការស៊ើបអង្កេត និងផែនការជួយសង្គ្រោះ ដែលដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្រុមជួញដូរកុមារសំរាប់បំរើផ្លូវភេទ នៅស្វាយប៉ាក ត្រូវបានគេជឿថាមានខ្សែរឹងមាំ ហើយត្រូវបានការពារពីការស៊ើបអង្កេត និងការកាត់ទោសរបស់រដ្ឋាភិបាល។ ប្រភពមួយចំនួនដែលដឹងរឿង បានរាយការណ៍ថា មន្ត្រីរដ្ឋាភិបាលមានការពាក់ព័ន្ធក្នុងការជ្រើសរើសពលករកម្ពុជាទៅធ្វើការនៅបរទេស។ រឿងនេះត្រូវបានគេជឿថា ជាបុព្វហេតុនៃនិទន្តភាពរបស់ក្រុមហ៊ុនជ្រើសរើសមនុស្សដោយខុសច្បាប់  ដែលជាការរួមចំណែកដល់ការជួញដូរ។ ក្នុងអំឡុងឆ្នាំនៃរបាយការណ៍នេះ មានរបាយការណ៍ខ្លះនិយាយថា អាជ្ញាធរមានសមត្ថកិច្ចបានប្រាប់ជាមុនពីការចុះធ្វើអធិការកិច្ចនៅតាមក្រុមហ៊ុនជ្រើសរើសពលករ ដើម្បីអោយក្រុមហ៊ុនលាក់កុមារដែលត្រូវបានឃុំទុកនៅកន្លែងរបស់គេ ដោយមានខ្លះអាចជាជនរងគ្រោះដោយការជួញដូរ។ នៅខែមិនា ឆ្នាំ ២០១១ អាជ្ញាធរបានចាប់នគរបាលពាក់ស័ក្តបួនម្នាក់ពីបទពុករលួយទាក់ទងនឹងការជួញដូរ ហើយបានរាយការណ៍ពីការងារជាបន្តក្នុងការស៊ើបអង្កេតលើករណីនេះដែលនៅតែកំពុងបន្តនៅឡើយក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ អាជ្ញាធរថែមទាំងបានរាយការណ៍ពីការកាត់និងដាក់ទោសលើស្មៀនឃុំម្នាក់ នៅខែកុម្ភៈ ឆ្នាំ ២០១១ ពីបទទទួលសំណូកដើម្បីក្លែងឯកសារអាយុដើម្បីអោយកុមារម្នាក់អាចទៅធ្វើការនៅក្រៅប្រទេសបាន។ គាត់ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារចំនួន ៥ ឆ្នាំ តែនឹងត្រូវបានដោះលែងបន្ទាប់ពីរយៈពេល ១ ឆ្នាំ។

## ការការពារ (Protection)

រាជរដ្ឋាភិបាលកម្ពុជាមិនបានបង្កើនការខិតខំរបស់ខ្លួន ដើម្បីកំណត់ និងផ្តល់ការការពារដល់ជនរងគ្រោះដោយការជួញដូរមនុស្សទេ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ។រដ្ឋាភិបាលបានបន្តបញ្ជូនជនរងគ្រោះទៅកន្លែងទទួលស្នាក់នៅរបស់អង្គការមិនមែនរដ្ឋាភិបាល តែខ្លួនមិនផ្តល់ជំនួយអ្វីថែមទេ ។ នៅតែមានបញ្ហានៃការខ្វះទីកន្លែងជំរកសំរាប់មនុស្សប្រុស និងកុមារា ដែលជាជនរងគ្រោះដោយសារការជួញដូរ។ រដ្ឋាភិបាលមិនបានផ្តល់ស្ថិតិនៃចំនួនសរុបនៃជនរងគ្រោះដោយសារការជួញដូរ ដែលត្រូវបានរកឃើញ និងជួយដោយអាជ្ញាធរ ក្នុងអំឡុងពេលនៃរបាយការណ៍នេះទេ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារនិតិសម្បទារ (MOSAVY) បាននិយាយពីការជួយក្នុងការរកកន្លែងស្នាក់នៅបណ្តោះអាសន្ន សំរាប់ជនរងគ្រោះចំនួន ៥៩៥ នាក់ ដែលត្រូវបញ្ជូនដោយនគរបាលមូលដ្ឋាន និង ៥០១ នាក់ទៀតដែលត្រូវបានបញ្ជូនពីអាជ្ញាធរបរទេសក្នុងឆ្នាំនៃរបាយការណ៍នេះ។ ក្រសួងសង្គមកិច្ចបានបន្តការងារជាមួយអង្គការ UNICEF ក្នុងមជ្ឈមណ្ឌលស្នាក់នៅបណ្តោះអាសន្ន នៅប៉ោយប៉ែត សំរាប់ជនរងគ្រោះដែលត្រឡប់មកពីប្រទេសថៃវិញ ហើយបាននិយាយថា បានរកឃើញជនរងគ្រោះចំនួន ១១៩ នាក់ដែលត្រូវបានចាប់បញ្ជូនត្រឡប់វិញដោយអាជ្ញាធរថៃ ក្នុងអំឡុងឆ្នាំនៃរបាយការណ៍នេះ។ រដ្ឋាភិបាលបានធ្វើការជាមួយដៃគូជាអង្គការមិនមែនរដ្ឋាភិបាលដើម្បីធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជាស្ត្រីចំនួន ៥ នាក់ទៅប្រទេសវៀតណាម ក្នុងអំឡុងពេលនៃរបាយការណ៍។

អាជ្ញាធរបានលើកទឹកចិត្តអោយជនរងគ្រោះចូលរួមក្នុងការស៊ើបអង្កេត និងការយកមកកាត់ទោសនូវជនប្រព្រឹត្តការជួញដូរ។ ប៉ុន្តែ ប្រព័ន្ធអនុវត្តច្បាប់ និងប្រព័ន្ធតុលាការដ៏ខ្សោយ និងពុករលួយ ដំណើរការក្តីយូរ ការភ័យខ្លាចចំពោះការសងសឹក ហើយនិងកង្វះការការពារសាក្សីនៅតែជាឧបសគ្គមិនអោយជនរងគ្រោះមានចិត្តចង់ធ្វើសហប្រតិបត្តិការក្នុងករណីនានា ហើយជាឧបសគ្គចំពោះការទទួលបានយុត្តិធម៌តាមផ្លូវច្បាប់។ លើសពីនេះទៀត អាជ្ញាធរមិនបានធ្វើការប្រឹងប្រែងបានគ្រប់គ្រាន់ ដើម្បីផ្តល់អោយកុមារ និងជនរងគ្រោះនូវកន្លែងសមរម្យសំរាប់អ្នកដែលរង់ចាំផ្តល់កសិណសាក្សី ដែលជាការបង្ខំអោយជនរងគ្រោះនៅកន្លែងជាមួយជនល្មើសដែលបានជួញដូររូបគេ។ ថ្វីបើជនរងគ្រោះអាចមានជំរើសតាមផ្លូវច្បាប់ក្នុងការដាក់បណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនល្មើសជួញដូរក្តី តែភាគច្រើនគ្មានលទ្ធភាពធនធានសំរាប់ដាក់បណ្តឹងនេះទេ ហើយរដ្ឋាភិបាលមិនបានផ្តល់ជំនួយដល់ជនរងគ្រោះក្នុងរឿងនេះទេ។ ក្រៅពីនេះទៀត ថ្វីបើច្បាប់ឆ្នាំ ២០០៨ អនុញ្ញាតអោយជនរងគ្រោះទាមទារសំណងពីជនល្មើសជួញដូរលើរូបគេក្តី តែជនរងគ្រោះត្រូវរង់ចាំរហូតទាល់តែជនល្មើសចេញពីពន្ធនាគារវិញ ទើបអាចទទួលសំណងបាន។

## ការរាំងខ្ទប់កុំអោយកើតមាន (Prevention)

ការប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការរាំងខ្ទប់កុំអោយមានការជួញដូរ ក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ នៅតែមិនមានភាពពេញលេញ។ រដ្ឋាភិបាលបានបន្តការខិតខំខ្លះ ដោយមានការជួយពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល តែមិនបានខិតខំក្នុងការរារាំងមិនអោយមានការជួញដូរពលករចំណាកស្រុកកម្ពុជា ឬកាត់បន្ថយអោយបានធំដុំនូវតំរូវការផ្លូវភេទតាមរយៈការជួញដូរក្នុង ស្រុកទេ។ អាជ្ញាធរបន្តចចារលើកិច្ចព្រមព្រៀងពលកម្មបន្ថែមជាមួយប្រទេសដទៃ នៅអាស៊ី និងមជ្ឈឹមបូព៌ា។ ច្បាប់កម្ពុជាស្តីពីការជ្រើសរើស ការរកកន្លែងការងារអោយធ្វើ និងការការពារពលករចំណាកស្រុកនៅមានកំរិត និងហួសសម័យ។ ច្បាប់ទាំងនោះខ្វះការរៀបរាប់បញ្ជាក់ពីការទទួលខុសត្រូវរបស់ទីភ្នាក់ងារជ្រើសរើសពលករក្នុងអំឡុងពេលនៃដំណើរការជ្រើសរើស មិនលំអិតពីការគ្រប់គ្រងនិងតាមដានអោយបានសមរម្យលើទីភ្នាក់ងារ ដើម្បីជៀសវាងការប្រព្រឹត្តល្មើស ហើយមិនកំណត់ទោសចំពោះការធ្វើមិនគប្បីរបស់ទីភ្នាក់ងារ។ លើសពីនេះទៀត គ្មានគោលនយោបាយដែលគ្រប់គ្រង ដាក់កំហិត ឬធ្វើអោយមានលក្ខណៈឯកភាពដូចគ្នាលើទឹកប្រាក់ដែលទីភ្នាក់ងារជ្រើសរើសអាចទារពីពលករ។ ក្នុងឆ្នាំនៃរបាយការណ៍នេះ រដ្ឋាភិបាលបានធ្វើពង្រាងអនុក្រិត្យស្តីពីការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករអន្តរជាតិ តែអនុក្រិត្យនោះមិនត្រូវបានអនុម័តទេ គិតមកដល់ខែមេសា ឆ្នាំ ២០១១។ អង្គការមិនមែនរដ្ឋាភិបាលបាននិយាយពីការដែលរដ្ឋាភិបាលដាក់កំរិតព្រំដែនលើការចូលរួមរបស់ពួកគេក្នុងការពិគ្រោះយោបល់ស្តីពីអនុក្រិត្យនោះ ដោយទន្ទឹមនឹងនោះ អនុញ្ញាតអោយមានការបញ្ចេញមតិច្រើនពីសមាគមនៃទីភ្នាក់ងារជ្រើសរើសពលករកម្ពុជាដែលជាក្រុមតំណាងអោយទីភ្នាក់ងារដែលអនុក្រិត្យនោះមានបំណងធ្វើអោយប្រព្រឹត្តបានត្រឹមត្រូវ។ ពលករចំណាកស្រុកខ្មែរនៅបរទេសមិនសូវយល់ពីកន្លែងដែលគេអាចផ្ញើបណ្តឹងតវ៉ាទាក់ទងនឹងរឿងរបស់គេក្នុងការងារ ហើយរបាយការណ៍នានាបង្ហាញថា នៅពេលតំណាងរដ្ឋាភិបាលធ្វើអន្តរាគមក្នុងដំណោះស្រាយជំលោះ ជាទូទៅ គេចចារអោយទីភ្នាក់ងារជ្រើសរើសពលករ ជាជាងអោយកម្មករចំណាកស្រុក។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ក្រសួងការងារបាននិយាយថា ខ្លួនបានចាប់ផ្តើមផ្តល់ការបង្រៀនមុនពេលចេញដំណើរសំរាប់អនាគតពលករ ស្តីពីសិទ្ធិរបស់គេ។

នៅខែមិនា រដ្ឋាភិបាលបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មក្នុងក្រសួងសង្គមកិច្ច។ ក្រសួងបានប្រារព្ធ "ទិវាប្រឆាំងការជួញដូរមនុស្ស" នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១០ នៅភ្នំពេញ សៀមរាប និងបន្ទាយមានជ័យ។ ក្រសួងកិច្ចការនារីបានធ្វើជាដៃគូជាមួយអង្គការអន្តោប្រវេសន៍ (IOM) ដើម្បីធ្វើយុទ្ធនាការស្តីពីការធ្វើអន្តោប្រវេសន៍ប្រកបដោយសុវត្ថិភាព នៅតាមខេត្តមួយចំនួន ហើយបានចូលរួមក្នុងការសំភាសន៍តាមវិទ្យុ ដោយលើកកំពស់ការយល់ដឹងពីការជួញដូរតាមរយៈការរៀបការ។ ពិតមែនតែតំរូវការរបស់មនុស្សក្នុងស្រុកមានលើសលុបលើតំរូវការការជួញដូរមនុស្សក្តី តែរដ្ឋាភិបាលមិនបានប្រឹងប្រែងដើម្បីកាត់បន្ថយតំរូវការរបស់មនុស្សក្នុងស្រុកទៅលើសកម្មភាពជួញដូរផ្លូវភេទឡើយ ក្នុង

អំឡុងនៃរបាយការណ៍នេះ។ ក្រសួងទេសចរណ៍បានបន្តការខិតខំជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើផ្ទាំងប៉ាណូ ការផ្សព្វផ្សាយតាមទស្សនាវដ្ដី  និងក្រដាសចែកចាយ ដើម្បីបន្ថយតំរូវការការជួញដូរផ្លូវភេទថ្វីបើការខិតខំទាំងនេះសំដៅទៅលើទេចរផ្លូវភេទបរទេស ជាជាងមនុស្សនៅក្នុងស្រុកក្ដី។ អាជ្ញាធរបានផ្ដន្ទាទោសទេសចរផ្លូវភេទបរទេសចំនួន ៨ នាក់ ដែលរួមភេទជាមួយកុមារ ក្នុងឆ្នាំនៃរបាយការណ៍នេះហើយបានផ្ដើមកាត់ទោសជនបរទេស ៧ នាក់ទៀត។ កងកំលាំងយោធាកម្ពុជាដែលចូលរួមក្នុងសកម្មភាពថែរក្សាសន្តិភាពនៅបរទេស បានទទួលការបណ្ដុះបណ្ដាលស្ដីពីការជួញដូរមនុស្ស មុនពេលចាកចេញទៅបំពេញបេសកកម្ម។

---